## សេចក្តីថ្លែងការណ៍រួម

# សូមដោះលែង និងទម្លាក់ចោលបទចោទលើបុគ្គលិក CCFC ជាបន្ទាន់

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

ការចាប់ខ្លួនបុគ្គលិកបីរូបរបស់សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) និងការសម្រេចចោទប្រកាន់ដែលមិនសមហេតុផល ដែលបានចោទពីបទ រួមគំនិតក្បត់ និងញុះញង់ឱ្យប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម គឺជាករណីមួយបន្ថែមទៀត ដែលអាជ្ញាធរកម្ពុជាបានធ្វើឡើង ដើម្បីការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សចំពោះភាពសកម្មនិយមដោយអហិង្សារបស់ពួកគេ ។

យើងខ្ញុំជាក្រុមសង្គមស៊ីវិល ដែលមានរាយនាមដូចខាងក្រោម ទាមទារឱ្យបញ្ឈប់នូវការចោទប្រកាន់ដោយគ្មានមូលដ្ឋានចំពោះអ្នកការពារសិទ្ធិមនុស្សទាំងអស់ និងសូមអំពាវនាវឱ្យដោះលែងបុគ្គលិកសមាគម CCFC ទាំងបីរូបជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ ដើម្បីអ្នកទាំងបីមានសេរីភាពក្នុងការបំពេញការងារសំខាន់ៗបន្តទៀត ។

កាលពីព្រឹកថ្ងៃទី ១៨ ខែឧសភា នគរបាលបានសម្រេចឃាត់ខ្លួនលោក ថេង សាវឿន ប្រធានសមាគម CCFC លោក ញិល ភាព មន្ត្រីជាន់ខ្ពស់សមាគម និងលោក ថាន់ ហាច មន្ត្រីសម្របសម្រួលសហគមន៍ ជាផ្លូវការ។ ពួកគេត្រូវបានចាប់ឃាត់ខ្លួនជាលើកដំបូងក្នុងខេត្តក្រចេះ នៅតាមផ្លូវទៅរាជធានីភ្នំពេញកាលពីថ្ងៃទី ១៧ ខែឧសភា ខណៈពេលដែលពួកគេកំពុងតែធ្វើដំណើរជាមួយនឹងមនុស្សរាប់សិបនាក់ផ្សេងទៀត ក្រោយពីចូលរួមកម្មវិធីនៅឯខេត្តរតនគិរី ហើយក្រោយមកអ្នកទាំងនោះត្រូវបាននគរបាលបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលខេត្តរតនគិរី ។

មានតែ សាវឿន ទេ ដែលបានជួបនិយាយជាមួយមេធាវី នៅថ្ងៃទី១៩ ខែឧសភា នៅស្នងការដ្ឋាននគរបាលខេត្តរតនគិរី បន្ទាប់ពីការឃាត់ខ្លួនគាត់នៅខេត្តក្រចេះ និងមុនពេលបញ្ជូនទៅសាលាដំបូងខេត្តរតនគិរី ។ នៅថ្ងៃទី២២ ខែឧសភា មេធាវីត្រូវបានអនុញ្ញាតឱ្យជួបកូនក្តីម្តងទៀត អំឡុងពេលការសាកសួរចម្លើយនៅតុលាការខេត្តរតនគិរី ។

កាលពីរសៀលថ្ងៃ ២២ ខែឧសភា ចៅក្រមស៊ើបសួរ លោក សាយ គួហាវ បានសម្រេចចោទប្រកាន់លោក ថេង សាវឿន លោក ញិល ភាព លោក ថាន់ ហាច ពីបទ រួមគំនិតក្បត់ មាត្រា ៤៥៣ និងបទ ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។ អ្នកទាំងបីប្រឈមនឹងជាប់ពន្ធនាគារដល់ ១០ ឆ្នាំ និងពិន័យជាទឹកប្រាក់រហូតដល់ ៤ លាន រៀល (ប្រហែល១.000 ដុល្លារ) ប្រសិនបើរកឃើញថាមានទោស ។ ដោយឡែកយោងតាមសេចក្តីថ្លែងការណ៍របស់សាលាដំបូងខេត្តរតនគិរី លោកបណ្ឌិត ចាន់ វិបុលក៏ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសដូចអ្នកទាំងបីខាងលើផងដែរ ។

ការចោទប្រកាន់ទាំងនេះ គឺជាការចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ។ សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) គឺជាសមាគមកសិករមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ ហើយធ្វើការជាមួយសហគមន៍ ជាង ៧0 សហគមន៍នៅទូទាំង ១០ ខេត្ត ដើម្បីជួយដល់កសិករដែលរងគ្រោះដោយការប

ណ្ដោញចេញ និងលើកកម្ពស់សិទ្ធិដីធ្លីដែលជាតម្រូវការចាំបាច់បំផុត ។ សមាគមធ្វើការជួយគាំទ្រដល់សហគមន៍ឱ្យយល់ដឹងពីសិទ្ធិ និងការតស៊ូមតិ ដើម្បីការរស់ល្អប្រសើរ និងសិទ្ធិមានដីធ្លីសម្រាប់កសិករទាំងអស់នៅទូទាំងប្រទេស ។

ការងាររបស់សកម្មជនសិទ្ធិមនុស្ស មិនត្រូវប្រដូចនឹងសកម្មភាពបទល្មើសព្រហ្មទណ្ឌ ដូចជាការញុះញង់ ឬរួមគំនិតក្បត់ប្រឆាំងនឹងជាតិ ឡើយ ។ ការចាប់ខ្លួនបុគ្គលិកសមាគម CCFC នឹងមិនអាចដោះស្រាយបញ្ហាជម្លោះដីធ្លីដ៏រ៉ាំរ៉ៃ ដែលបានកើតឡើងមកលើសមាជិករបស់សមាគមនោះទេ ។ ហើយវាក៏នឹងមិនអាចបំបិទសំឡេងរបស់អ្នកដឹកនាំនិងតំណាងសហគមន៍ ដែលកំពុងទាមទាររកយុត្តិធម៌សម្រាប់សមាជិកសហគមន៍ មិត្តភក្តិ និងក្រុមគ្រួសាររបស់ពួកគេ ។

ការចាប់ខ្លួនទាំងនេះ ធ្វើឱ្យកើតឡើងនូវការតវ៉ាជាច្រើនថ្ងៃពីសំណាក់សហគមន៍នៅទូទាំងប្រទេស ដែលសហគមន៍ទាំងនោះដឹងយ៉ាងច្បាស់ថា ការចាប់ខ្លួនគឺដើម្បីរារាំងភាពសកម្មនិយមរបស់ពួកគេ ហើយនិងរារាំងការស្វែងរកដំណោះស្រាយទៅលើបញ្ហាដីធ្លីរបស់ពួកគេ ។

អាជ្ញាធរត្រូវដោះលែង លោក ថេង សាវឿន លោក ញិល ភាព និង លោក ថាន់ ហាច ជាបន្ទាន់ ហើយបទចោទប្រកាន់ទាំងអស់ គួរត្រូវទម្លាក់ចោល ។ ការប្រមូលផ្តុំរបស់សហគមន៍មូលដ្ឋាន មិនមែនជាបទឧក្រិដ្ឋ ។ ការដោះលែងសកម្មជនទាំងនេះ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកសន្តិភាព និងយុត្តិធម៌ពិតប្រាកដ សម្រាប់ទាំងអស់គ្នា ៕

*សេចក្តីថ្លែងការណ៍រួមចូលរួមគាំទ្រដោយ៖*

1. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
2. សហគមន៍ដីធ្លីភូមិព្រលាន ២៤៣ (កោះកុង)
3. សហគមន៍កសិករក្រីក្រជនបទ ៩៥៥ (កោះកុង)
4. សហគមន៍អមលាំង (កំពង់ស្ពឺ)
5. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
6. សហគមន៍បុស្សស្នោរ (ត្បូងឃ្មុំ)
7. សម្ព័ន្ធសហជីពកម្ពុជា (CATU)
8. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
9. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
10. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
11. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
12. សហភាពការងារកម្ពុជា (CLC)
13. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
14. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
15. បណ្តាញយុវជនកម្ពុជា (CYN)

16. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
17. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
18. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ (រតនគិរី)
19. សហគមន៍ដីធ្លីដីខក្រោម (កោះកុង)
20. សហគមន៍ដីធ្លីដីខលើ (កោះកុង)
21. សហគមន៍ដាំក្រវៀន (ត្បូងឃ្មុំ)
22. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
23. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
24. សហគមន៍ដក់ពរ (កំពង់ស្ពឺ)
25. អង្គការសមធម៌កម្ពុជា (EC)
26. សហជីពសេរីកម្មករនៃព្រះរាជាណាចក្រ (FTUWKC)
27. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
28. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
29. សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរុខេត្តព្រះវិហារ
30. សហគមន៍ឃុំស្រុកថ្លុកឫស្សី (កំពង់ធំ)
31. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
32. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
33. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើល (L.R.S.U)
34. សហគមន៍ដីធ្លីខេត្តប៉ៃលិន
35. សហគមន៍មានជ័យ (ស្វាយរៀង)
36. សហគមន៍ពាមរស់ (កំពង់ស្ពឺ)
37. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)
38. សហគមន៍ភ្នំក្រោម (សៀមរាប)
39. សហគមន៍ភ្នំទទឹង (កំពត)
40. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
41. សហគមន៍ដីធ្លីព្រែកខ្សាច់ (កោះកុង)
42. សហគមន៍ព្រៃឈើពេជ្រចង្វារល្អធើត (កំពង់ឆ្នាំង)
43. សហគមន៍ព្រៃឡង់ (ព្រះវិហារ)
44. សហគមន៍ដីធ្លីព្រៃពាយ (កំពត)
45. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
46. សហគមន៍ស្មើសាមគ្គី (កំពង់ស្ពឺ)
47. សមាគមជាងត្នោត (STT)
48. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
49. សហគមន៍សាមគ្គីមាសហែក (ស្វាយរៀង)

50. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
51. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
52. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
53. សហគមន៍ដីធ្លីតានី (សៀមរាប)
54. សហគមន៍ដីធ្លីតានូន (កោះកុង)
55. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
56. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
57. សហគមន៍ថ្មដា (ពោធិ៍សាត់)
58. សហគមន៍ទន្លូង (ត្បូងឃ្មុំ)
59. សហគមន៍ត្រពាំងដោ (កំពង់ស្ពឺ)
60. សហគមន៍ត្រពាំងព្រីង(ត្បូងឃ្មុំ)
61. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)